# ឧស្ម័ន ក្លរីន (Chlorine Gas)

## អ្វីទៅ ឧស្ម័ន ក្លរីន នោះ ?

ឧស្ម័ន ក្លរីន ចេញមកពីជាតិ ក្លរីន, វាជាជាតិគីមីទូទៅប្រើប្រាស់ទូទៅនៅរោងចក្រ, មន្ទីរពិសោធន៍ ហើយនិងក្នុងវត្ថុប្រើប្រាស់នៅក្នុងផ្ទះសំបែងខ្លះ។ នៅពេលណាទឹក ក្លរីន លាយខ្យល់, វាបង្កើតជាតិឧស្ម័ន ក្លរីន ។

## តើឧស្ម័ន ក្លរីន មានរូបរាងយ៉ាងម៉េចដែរ ?

- វាមានពណ៌លឿង-បៃតង ហើយមានក្លិនខ្លាំង, ដូចជាជាតិថ្នាំធ្វើឲ្យស, ហើយ
- ជាតិនេះស្ថិននៅជិតនិងដី ហើយរាលដាលលឿនណាស់។

## តើខ្ញុំប្រហែលជានឹងមានការប៉ះពាល់ដល់ជាតិឧស្ម័ន ក្លរីន ដោយរបៀបណា ?

លោកអ្នកប្រហែលជាអាចប៉ះពាល់ដល់ជាតិឧស្ម័ន ក្លរីន បើសិនជា :

- លោកអ្នកលាយថ្នាំធ្វើឲ្យសសំរាប់ប្រើប្រាស់ក្នុងផ្ទះជាមួយនិងវត្ថុសំអាតផ្សេងៗទៀត,
- មានគ្រោះថ្នាក់កើតឡើងនៅផ្នែកឧស្សាហកម្ម, ឬ
- មានភេរវជនបញ្ចេញជាតិឧស្ម័ន ក្លរីន តាមខ្យល់។

## តើជាតិឧស្ម័ន ក្លរីន គ្រោះថ្នាក់ឬទេ ?

គ្រោះថ្នាក់។ ជាតិឧស្ម័ន ក្លរីន គឺជាជាតិពុល។ បើសិនជាលោកអ្នកស្រូបដង្ហើមចូលជាតិនេះ លោកអ្នកអាចស្លាប់បាន។

## តើវាមានរោគសញ្ញាយ៉ាងណាដែរ ?

ជាតិឧស្ម័ន ក្លរីន មួយចំនួនធំអាចធ្វើឲ្យប៉ះពាល់យ៉ាងលឿន :

- រលាកក្នុងច្រមុះ, បំពង់ក, ហើយនិងភ្នែក
- ឈឺចុកចាប់, ឡើងពងក្រហម, ហើយឡើងពងលើស្បែក
- ហៀរទឹកភ្នែក, ព្រិលភ្នែក
- ក្អក និងពិបាកដកដង្ហើម
- ចង្អោររកក្អួត និងក្អួត

បើជាតិឧស្ម័ន ក្លរីន មានកំរិតតិច, រោគសញ្ញាប្រហែលជាកើតឡើងនៅពេលក្រោយ។

## តើខ្ញុំនឹងស្លាប់ដោយសារដកដង្ហើមស្រូបចូលជាតិឧស្ម័ន ក្លរីន ឬទេ ?

វាស្រេចតែទៅលើចំនួនជាតិឧស្ម័នលោកអ្នកដកដង្ហើមស្រូបចូល។ បើសិនជាលោកអ្នកមិនស្លាប់, លោកអ្នកនឹង ត្រូវតែស្នាក់នៅក្នុងមន្ទីរពេទ្យដើម្បីព្យាបាល។

## តើខ្ញុំធ្វើយ៉ាងណាបើសិនជាខ្ញុំគិតថាមានការប៉ះពាល់ដល់ជាតិឧស្ម័ន ក្លរីន នោះ ?

- **ចេញពីកន្លែងនោះ។**
- **ដោះសំលៀកបំពាក់ចេញ, ស្បែកជើង និងវ៉ែនតា ឬកែវពាក់ក្នុងភ្នែក។** ជៀសវាងកុំដោះអាវទាញរំលងក្បាលរបស់លោកអ្នក។ វាប្រហែលជាអាចមានជាតិ ក្លរីន នៅលើខោអាវនោះ។ ចូរកាត់ខោអាវនោះចេញវិញ។



- **លាង ឬងូតលាងខ្លួនរបស់លោកអ្នក។** ប្រើសាប៊ូឲ្យបានច្រើន, បើសិនជាមាន។
- **លាងភ្នែករបស់លោកអ្នក**ជាមួយទឹកឲ្យបាន 10 ទៅ 15 នាទី, បើសិនជាមានក្រហាយក្នុងភ្នែក។ លោកអ្នកអាចពាក់វ៉ែនតាវិញបានបើសិនជាលោកអ្នកលាងវារួចហើយ។ កុំប្រើកែវពាក់ក្នុងភ្នែកវិញឲ្យសោះ។



- *ទូរស័ព្ទទៅលេខ 911 ដើម្បីស្នើសុំការព្យាបាលភ្លាមៗ !*

បន្ទាប់មកប្រព្រឹត្តធ្វើតាមប្រការទាំងនេះ :

- ○ **ដាក់ខោអាវដែលប៉ះប្រឡាក់និងជាតិនេះ និងកែវពាក់ក្នុងភ្នែកក្នុងថង់ប្លាស្ទីក ហើយចងវាឲ្យជិត។** (ការពារដៃរបស់លោកអ្នកដោយពាក់ស្រោមដៃជ័រ ឬថង់ប្លាស្ទីក)។ ដាក់ថង់នោះនៅក្នុងថង់ប្លាស្ទីកមួយទៀត ហើយចងវាឲ្យជិត។
- ○ ចូរប្រាប់ក្រុមអ្នកជួយសង្គ្រោះជាបន្ទាន់កន្លែងដែលលោកអ្នកបានដាក់ថង់នោះ។

## សំរាប់ពត៌មានបន្ថែម...

ទូរស័ព្ទទៅ CDC (Centers for Disease Control) សំរាប់ពត៌មានជាភាសាអង់គ្លេស :

800-CDC-INFO (800-232-4636)
888-232-6348 (TTY)

ឬទស្សនាគេហទំព័រ : www.bt.cdc.gov/chemical
www.dhs.ca.gov/epo